**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៧៩៧ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១២

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ មេត្តាជ្រាបថា ក្នុងអំឡុងពេលជិតបញ្ចប់ការប្រមូលពន្ធលើអចលនទ្រព្យក្នុងអំឡុងការពន្យារពេលកន្លងមក ឃើញថានៅមានម្ចាស់អចលនទ្រព្យជាច្រើននៅបាននិងកំពុងមមាញឹកមកប្រកាសបង់ពន្ធនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ជាហេតុធ្វើឱ្យការផ្តល់សេវាជូនអ្នកជាប់ពន្ធមិនបានទាន់ពេលវេលា ។

ដូចនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលប្រមូលពន្ធលើអចលនទ្រព្យបន្តទៀត រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ ។

ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួលដល់ម្ចាស់អចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំចាត់ចែងផ្តល់សេវាប្រមូលពន្ធនៅថ្ងៃសៅរ៍-អាទិត្យ បន្ថែមទៀត ។

អគ្គនាយកដ្ឋានពន្ធដារ មានក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអំឡុងពេលពន្យារនេះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា និងចប់សព្វគ្រប់ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ ខាងមុខនេះ ជាមិនខាន ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (855) 23 886 700